# សជ្ឈាយនា



រៀបរៀងដោយ

**ភិក្ខុ ចិន ភេន ឥន្ទប្បញ្ញោ**

វត្តពោធិវង្ស ប្រទេសបារាំង

ព.ស.២៥៤១ គ.ស.១៩៩៧

# សាមគ្គីគ្នា ជាតិ សាសន៍ រស់
# ឈ្លោះបាក់បែកគ្នា ជាតិ សាសន៍ ស្លាប់
# សាមគ្គីគ្នា ល្អចំណាប់
# ជាតិ សាសន៍ មិនស្លាប់ រស់ថ្កើងថ្កាន

*បើមានកំហុសឆ្គងក្នុងការវាយពុម្ពអក្សរនេះ សូមលោកអ្នកអានមេត្តាជួយកែលម្អឲ្យបានត្រឹមត្រូវឡើងវិញផង*

*អរគុណ* !!!

**ម.ឧត្តម**

៣/១១/២០១៣

# សេចក្តីផ្តើម

ក្នុងឱកាសបុណ្យឆ្លងគម្ពីរព្រះត្រៃបិដក វត្តពោធិវង្ស ប្រទេសបារាំង នៅថ្ងៃទី ៨ មិថុនា ១៩៩៧ នេះ ខ្ញុំគិតថា គួរនឹងសរសេរកូនសៀវភៅធម៌អ្វីមួយ ដែលជាប់ទាក់ទងនឹងគម្ពីរព្រះត្រៃបិដក បោះពុម្ពចែកជាធម្មទាន។ ខ្ញុំនឹកឃើញថា រឿងសជ្ឈាយនា ជាហេតុមួយនាំឲ្យមានគម្ពីរព្រះត្រៃបិដក ទើបចាប់សរសេររឿងនេះភ្លាម ដោយប្រើពេលយ៉ាងខ្លីបំផុត។ ខ្ញុំជឿជាក់ថា កូនសៀវភៅតូចនេះ និយាយមិនបានសព្វគ្រប់ទេ ហើយអាចនឹងមានការភ្លាំងភ្លាត់ខ្លះជាមិនខាន ព្រោះប្រញាប់ប្រញាល់ពេក។ ប៉ុន្តែ ខ្ញុំត្រេកអរនឹងទទួលមតិពីលោកអ្នកទាំងឡាយ ដើម្បីកែសម្រួលកូនសៀវភៅនេះ ឲ្យបានសមរម្យឡើងថែមទៀត ទៅអនាគតកាល។

ខ្ញុំសង្ឃឹមថា កូនសៀវភៅនេះ នឹងបានជាប្រយោជន៍ខ្លះ ដល់លោកអ្នកអាន ជាពុំខាន។

វត្តពោធិវង្ស, ថ្ងៃទី ៨ មិថុនា ១៩៩៧

**ភិក្ខុ ខិន តេន ឥន្ទប្បញ្ញោ**

# សង្គាយនា

## នមត្ថុ រតនត្តយស្ស

ពាក្យថា **សង្គាយនា** តាមភាសាអ្នកស្រុក គេសំដៅយកព្រះសង្ឃទេសនាគ្រែបី បើទេសនាគ្រែពីរ គេហៅថា បុច្ឆា-វិសជ្ជនា។ ប៉ុន្តែ តាមភាសាធម៌ ពាក្យថា សង្គាយនា គេសំដៅយកការប្រជុំពិនិត្យផ្ទៀងផ្ទាត់រៀបចំដោយក្រងធម៌វិន័យ។ ការរៀបចំដោតក្រងធម៌វិន័យ មានមកតាំងពីសម័យពុទ្ធកាលម្ល៉េះ ព្រះពុទ្ធផ្ទាល់ព្រះអង្គបានចាត់ចែងព្រះធម៌វិន័យទុកជាពួកជាក្រុមហើយ ប៉ុន្តែ ព្រះអង្គសម្តែងធម៌វិន័យច្រើនដង ច្រើនលើក អស់រយៈពេលច្រើនដល់ទៅ ៤៥ ឆ្នាំ ពួកសាវកអាចនឹងចេះចាំ មិនបានទូទៅសព្វគ្រប់ អង្គខ្លះចេះត្រង់នេះ អង្គខ្លះចេះត្រង់នោះ ម្ល៉ោះហើយត្រូវតែមានការប្រជុំពិនិត្យផ្ទៀងផ្ទាត់គ្នាឲ្យបានញឹកញាប់។

ក្រោយពី និគណ្ឋនាដបុត្រ ធ្វើមរណកាលទៅថ្មីៗ ពួកនិគ្រន្ថអន្យតិរ្ថិយ៍ បែកគ្នាជាពីរពួក។ ព្រះចុន្ទត្ថេរ ជាប្អូនរបស់ព្រះសារីបុត្ត បានឃើញហេតុការណ៍មិនស្រួលដូចនោះ ក៏ចូលទៅរកព្រះអានន្ទ ហើយនាំគ្នាទៅក្រាបបង្គំគាល់ព្រះសម្មាសម្ពុទ្ធ ទូលស្នើតាមដំណើររឿងនោះ។ ព្រះពុទ្ធទ្រង់យសត្រាស់ថា ម្នាលចុន្ទ ព្រោះហេតុនោះ ធម៌ទាំងឡាយណាដែលតថាគតត្រាស់ដឹងហើយ សម្តែងទុកល្អហើយ ក្នុងលោកនេះ គួរអ្នកទាំងអស់រួមគំនិតមកប្រជុំផ្ទៀងផ្ទាត់នូវអត្ថដោយអត្ថ ព្យញ្ជនៈដោយព្យញ្ជនៈ ក្នុងធម៌នោះ ដែលជាហេតុឲ្យព្រហ្មចារ្យនេះ តាំងនៅមាំ ឋិតថេរអស់កាលយូរ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និង មនុស្ស ទាំងឡាយ[១]។

ពាក្យថា សង្គាយនា មានមកតាំងពីកាលនោះម្ល៉េះ ប៉ុន្តែ ពុទ្ធបរិស័ទ មិនទាន់និយមគ្នាប្រើនៅឡើយទេ លុះតែព្រះពុទ្ធអង្គទ្រង់បរិនិព្វានបាត់ទៅហើយ ទើបគេនាំគ្នាយកពាក្យនេះមកប្រើរៀងរហូតមក។

[១] *សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ បាសាទិកសូត្រ ១៨/២៣៧។ ក្នុងសង្គីតិសូត្រ ១៩/១២៣ មានសេចក្តីស្រដៀងគ្នានេះដែរ។*

# បឋមសង្គាយនា
## មូលហេតុដើម

ព្រះមហាកស្សប ព្រមដោយភិក្ខុសង្ឃ ៥០០ អង្គ និមន្តចេញពីក្រុងបាវា ឆ្ពោះទៅកាន់ក្រុងកុសិនារា ដើម្បីគាល់ព្រះសម្មាសម្ពុទ្ធ ជួនជាពេលនោះ បានជួបនឹងអាជីវកម្នាក់សៀតផ្កាមន្ទារវបុស្ប មកពីក្រុងកុសិនារា ព្រះមហាកស្សបក៏សួរថា អ្នកទើបនឹងមកពីក្រុងកុសិនារា តើបានដំណឹងអ្វីខ្លះ ពីសំណាក់ព្រះសមណគោតមបរមគ្រូរបស់យើងដែរ? អាជីវក ឆ្លើយប្រាប់ថា សមណគោតមជាគ្រូរបស់អ្នក បរិនិព្វានទៅ ៧ ថ្ងៃហើយ ផ្កាមន្ទារវបុស្បនេះ ខ្ញុំបានមកពីទីនោះឯង។ កាលបានឮដំណឹងនេះ បណ្ដាភិក្ខុសង្ឃទាំងឡាយណា ដែលមិនទាន់មានរាគៈទៅប្រាសហើយ ក៏យំសោកខ្សឹកខ្សួល ស្ដាយស្រណោះ អាឡោះអាល័យក្រៃពេក។ ចំណែក សុភទ្ទភិក្ខុបួសឯចាស់ក៏ពោលឡើងថា អ្នកទាំងឡាយកុំយំសោក ខ្សឹកខ្សួលឡើយ យើងរួចផុតស្រឡះហើយ កាលសមណគោតមគង់នៅ លោកតែងតែស្ដីបន្ទោសយើងរឿយៗ នេះគួរ នេះមិនគួរ បន្តិចខុសធម៌ បន្តិចខុសវិន័យ ឥឡូវនេះ លោកបរិនិព្វានហើយ ពួកយើងស្រួលហើយចង់ធ្វើអំពើអ្វីក៏ធ្វើអំពើនោះ បើមិនចង់ធ្វើអំពើអ្វី មិនចាំបាច់ធ្វើអំពើនោះទេ។ នេះជាបុព្វហេតុនៃបឋមសង្គាយនា។

ព្រះមហាកស្សប នាំភិក្ខុសង្ឃធ្វើដំណើរតទៅទៀត ដើម្បីចូលរួមក្នុងពិធីបុណ្យថ្វាយព្រះភ្លើងព្រះសម្មាសម្ពុទ្ធ លុះបានធ្វើបុណ្យស្រេចបាច់ហើយព្រះមហាកស្សប ក៏ប្រារព្ធដល់ពាក្យចម្រូងចម្រាស់នៃសុភទ្ទភិក្ខុបួសឯចាស់នេះ ជាមួយនឹងព្រះសង្ឃទាំងឡាយថា ព្រះពុទ្ធបរមគ្រូយើងបរិនិព្វានទៅទើបតែបាន ៧ ថ្ងៃប៉ុណ្ណោះ មានភិក្ខុអលជ្ជីពោលពាក្យចម្រូងចម្រាស់យ៉ាងនេះទៅហើយ យើងនៅស្ងៀមមិនសមគួរទេ ត្រូវតែប្រជុំគ្នាធ្វើសង្គាយនាពិនិត្យផ្ទៀងផ្ទាត់ដោតក្រងធម៌វិន័យទុកជាគ្រូរបស់យើង ដើម្បីសាសនាតាំងនៅអស់កាលជាយូរអង្វែងតទៅ។ ទីប្រជុំសង្ឃ បានព្រមព្រៀង ជ្រើសរើសយកព្រះអរហន្ត ដែលចេះចាំស្ទៀវស្ទាតធម៌វិន័យចំនួន ៥០០ អង្គ ដើម្បីចោទឆ្លើយផ្ទៀងផ្ទាត់ដោតក្រងធម៌វិន័យ។ ព្រះមហាកស្សប ជាប្រធាន អ្នកសួរ ព្រះឧបាលី ជាអ្នកឆ្លើយព្រះវិន័យ ព្រះអានន្ទ ជាអ្នកឆ្លើយព្រះធម៌ សម្រេចយកក្រុងរាជគ្រឹះជាទីកន្លែងប្រជុំ[២]។

[២] *វិន័យបិដក ចុល្លវគ្គ ១១/៣៩៦ ។*

# គោលខំខាន់នៃបឋមសង្គាយនា

១-ព្រះពុទ្ធបរិនិព្វានទៅបាន ៣ ខែ ចាប់ធ្វើការប្រជុំ។

២-ប្រជុំនៅ សត្តបណ្ណគូហា[៣] លើភ្នំវេភារៈ ក្រុងរាជគ្រឹះ ដែនមគធៈ ។

៣-ព្រះអរហន្ត ៥០០ អង្គ ចូលរួមប្រជុំ។

៤-ព្រះមហាកស្សប ជាប្រធាន អ្នកសួរ ព្រះឧបាលីត្ថេរ ជាអ្នកឆ្លើយព្រះវិន័យ ព្រះអានន្ទ អ្នកជាឆ្លើយព្រះធម៌។

៥-គោលបំណង ដើម្បីដោតក្រងធម៌វិន័យ ដើម្បីសាសនាតាំងនៅមាំ អស់កាលយូរ។

៦-ព្រះបាទអជាតសត្រូវ ជាអ្នកឧបត្ថម្ភក៏។

៧-ប្រជុំអស់ចិរវេលា ៧ ខែ ទើបសម្រេច ។

## ព្រះបុរាណៈជំទាស់

ពេលដែលព្រះថេរៈទាំងឡាយ ធ្វើបឋមសង្គាយនាចប់ស្រេចហើយ ព្រះបុរាណៈជាមួយនឹងភិក្ខុសង្ឃ ៥០០ អង្គ ត្រឡប់មកពីចារិកក្នុងទក្ខិណាគិរីជនបទ ចូលទៅរកភិក្ខុជាថេរៈក្នុងវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ លុះចូលទៅដល់អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះថេរៈទាំងឡាយនិយាយយ៉ាងនេះថា ម្នាលបុរាណៈដ៏មានអាយុ ធម៌ក្តី វិន័យក្តី ព្រះថេរៈទាំងឡាយបានសង្គាយនាស្រេចហើយ លោកចូរប្រកបនូវការសង្គាយនានោះចុះ។ ព្រះបុរាណៈឆ្លើយថា ម្នាលអាយុសោទាំងឡាយ ធម៌ក្តី វិន័យក្តី ដែលព្រះថេរៈទាំងឡាយ បានសង្គាយនាហើយជាការល្អ ប៉ុន្តែ ចំណែកខាងខ្ញុំ ធ្លាប់បានស្តាប់ បានទទួលក្នុងទីចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគយ៉ាងណា នឹងទ្រទ្រង់ទុកយ៉ាងនោះឯង[៤]។

នេះជាចំណុចមួយ សំដែងឲ្យឃើញថា ព្រះសង្ឃមិនសូវស្រុះស្រួលគ្នាទេ។ រឿងព្រះសង្ឃមិនស្រុះស្រួល ឬបែកខ្វែកគ្នានេះ មានជាលំអានមកតាំងពីពេលដែល

---

[៣] *គម្ពីរ ទីបេត៍ថា និគ្រោធគូហា។ អស្វរឃោសៈថា ឥន្ទសាលា ភ្នំគិជ្ឈកូដ ប៉ុន្តែស្របគ្នា ទីក្រុងរាជគ្រឹះ ។*

[៤] *វិន័យបិដក ចុល្លវគ្គ ១១/៣៧២។*

ព្រះសម្មាសម្ពុទ្ធគង់នៅម្ល៉េះ ឧទាហរណ៍ រឿងភិក្ខុចម្មកចិក និង ភិក្ខុវិន័យធរ[៥] រឿងភិក្ខុទេវទត្តបំបែកសង្ឃ[៦] ជាដើម។

## ទុតិយសង្គាយនា

ពុទ្ធសករាជកន្លងទៅបាន ១០០ ឆ្នាំ ពួកវជ្ជីបុត្តកភិក្ខុអ្នកក្រុងវេសាលី បានសំដែងឡើងនូវវត្ថុ ១០ ប្រការ ដែលជារបស់មិនគួរថាជារបស់គួរ គឺ៖

១-កប្បតិ សិង្គិលោណកប្បោ ភិក្ខុសន្សំអំបិលទុកក្នុងខ្លាក់ស្នែង ដោយគំនិតថា នឹង យកមកឆាន់ក្នុងពេលដែលមានវត្ថុសាប ក៏គួរ ។

២-កប្បតិ ទ្វង្គុលកប្បោ ភិក្ខុឆាន់ភោជនក្នុងវេលាវិកាលមានស្រមោលជ្រេទៅ ២ ធ្នាប់ ក៏គួរ។

៣-កប្បតិ គាមន្តរកប្បោ ភិក្ខុឆាន់រួចហើយ ហាមភោជនហើយ តាំងចិត្តនឹងចូលទៅក្នុងលង្វែងភូមិ ហើយឆាន់អនតិរិត្តភោជន ដែលមិនមែនជារបស់សំណល់ ក៏គួរ។

៤-កប្បតិ អាវាសកប្បោ អាវាសច្រើនក្នុងសីមាជាមួយគ្នា ភិក្ខុធ្វើសង្ឃកម្មមានឧបោសថកម្ម ជាដើមផ្សេងគ្នាក៏គួរ។

៥-កប្បតិ អនុមតិកប្បោ សង្ឃជាពួកធ្វើសង្ឃកម្មមិនរង់ចាំគ្នា ដោយគំនិតថា យើង នឹងឲ្យភិក្ខុដែលមកដល់អនុម័តិយល់ព្រម ជាខាងក្រោយ ក៏គួរ។

៦-កប្បតិ អាចិណ្ណកប្បោ ខបដិបត្តិដែលអាចារ្យ ឬឧបជ្ឈាយ៍ធ្លាប់ប្រព្រឹត្តមកសូម្បីខុស ក៏គួរ។

៧-កប្បតិ អមថិតកប្បោ ភិក្ខុឆាន់រួចហើយ ហាមភោជនហើយ ឆាន់ទឹកដោះស្រស់ មិនទាន់ក្លាយទៅជាទឹកដោះជូរ ដែលជាអនតិរិត្តភោជន ក៏គួរ។

៨-កប្បតិ ជលោគឹ បាតុំ ភិក្ខុឆាន់សុរាថោ "ខ្សោយ" ដែលនៅមិនទាន់ជាទឹកស្រវឹង ក៏គួរ។

---

[៥] វិន័យបិដក មហាវគ្គ ៨/៣០៤។

[៦] វិន័យបិដក ចុល្លវគ្គ ១១/៦២។

៩-កប្បតិ អទសកំ និសីទនំ សំពត់និសីទនៈ ដែលមិនមានជាយ ក៏គួរ។

១០-កប្បតិ ជាតរូបរជតំ ភិក្ខុទទួលមាសប្រាក់ ក៏គួរ[៧]។

សម័យនោះឯង ពួកវជ្ជីបុត្តភិក្ខុ ដងទឹកដាក់ពេញភាជនៈសំរឹទ្ធហើយយកទៅតម្កល់ទុកកណ្តាលជំនុំសង្ឃ ក្នុងថ្ងៃឧបោសថ រៃអង្គាសប្រាក់ពីពួកឧបាសក ឧបាសិកា ថា ព្រះសង្ឃនឹងកិច្ចដោយបរិក្ខារ ហើយយកប្រាក់នោះមកចែកគ្នា។ ព្រះយសកាកណ្ឌកបុត្ត ឃើញហេតុការណ៍មិនប្រពៃដូចនោះ ក៏ហាមឃាត់ថា ធ្វើយ៉ាងនេះ មិនត្រឹមត្រូវតាមធម៌វិន័យទេ។ ពួកវជ្ជីបុត្តភិក្ខុក៏រករឿងថា ព្រះយសកាកណ្ឌកបុត្ត ទំលាយសទ្ធារបស់ពួកពុទ្ធវិស័ទ ហើយធ្វើបដិសារណិយកម្មដល់លោក។ល។ ព្រះយសកាកណ្ឌកបុត្ត ជ្រាបថា ក្នុងអនាគតកាល ធម៌ជាអកុសលនឹងរុងរឿង ធម៌ជាកុសលនឹងសាបសូន្យ អធម្មវាទី នឹងមានកម្លាំង ធម្មវាទី នឹងថយកម្លាំងចុះ អវិនយវាទី នឹងមានកម្លាំង វិនយវាទី នឹងថយកម្លាំងចុះ.... ទើបត្រាច់ទៅប្រឹក្សានឹងព្រះមហាថេរ ទាំងឡាយ ដើម្បីរកឧបាយរម្ងាប់អធិករណ៍នេះ។ ពួកវជ្ជីបុត្តភិក្ខុ ដឹងដូចនោះ ក៏ចាត់គ្នាមានបរិក្ខារត្រៃចីវរជាដើមទៅប្រគេនព្រះមហាថេរ ដើម្បីបានជាបក្សពួក ប៉ុន្តែ លោកមិនឯកភាពផង និងចាត់អង្គខ្លះឲ្យទៅទាក់ទងជាមួយនឹងរដ្ឋអំណាច ដំបូងរដ្ឋអំណាចជួយគាំទ្រដែរ ប៉ុន្តែ ក្រោយមកដឹងថា មិនត្រូវតាមធម៌វិន័យ ក៏ត្រឡប់ជួយឧបត្ថម្ភ ព្រះយសកាកណ្ឌកបុត្តវិញ ដើម្បីរម្ងាប់អធិករណ៍ ធ្វើសង្គាយនា ពិនិត្យផ្ទៀងផ្ទាត់ធម៌វិន័យទុកជាក្បួនច្បាប់រៀងទៅ។ ការធ្វើសង្គាយនាលើកនេះ ធ្វើតាមលំអាននៃបឋមសង្គាយនា ដោយមានព្រះរេវតត្ថេរជាអ្នកសួរ ព្រះសព្វកាមីត្ថេរ ជាអ្នកឆ្លើយ។

## គោលសំខាន់នៃទុតិយសង្គាយនា

១-ព្រះពុទ្ធសករាជកន្លងទៅបាន ១០០ ឆ្នាំ

២-ព្រះអរហន្ត ៧០០ អង្គ ចូលរួមប្រជុំ។

៣-ព្រះសព្វកាមី ជាប្រធាន ព្រះរេវតត្ថេរជាអ្នកសួរ ព្រះសព្វកាមីត្ថេរជាអ្នកឆ្លើយ។

៤-ប្រជុំនៅវាលិការាម ក្រុងវេសាលី ដែនវជ្ជី។

---

[៧] *វិន័យបិដក ចុល្លវគ្គ ១១/៣៨៤។*

៥-គោលបំណង ដើម្បីរម្ងាប់អធិករណ៍ រឿងវត្ថុ ១០ ប្រការ និងពិនិត្យផ្ទៀងផ្ទាត់ធម៌វិន័យទុកជាក្បួនច្បាប់ល្អតទៅ។

៦-ព្រះបាទកាលាសោក ជាអ្នកឧបត្ថម្ភក៏។

៧-ប្រជុំអស់ថិរវេលា ៨ ខែ ទើបសម្រេច។

រឿង ទុតិយសង្គាយនា មានមូលហេតុមកពីពួកវជ្ជីបុត្តភិក្ខុសំដែងឡើងនូវវត្ថុ ១០ ប្រការ ដូចមានក្នុងគម្ពីរវិន័យបិដកចុល្លវគ្គ នោះស្រាប់ហើយ។ ប៉ុន្តែ គម្ពីរសំស្រ្កឹតឈ្មោះ ភេទធម្មតិចក្កសាស្រ្ត សំដែងថា មិនមែនមានមូលហេតុមកពីវត្ថុ ១០ ប្រការទេ តែមកពីមតិ ៥ ខ របស់មហាទេវៈ គឺ៖

១-ព្រះអរហន្ត អាចត្រូវមារ អូសទាញ ឬពន្យុះឲ្យយល់សប្តិបាន។

២-បុគ្គលអាចសម្រេចជាព្រះអរហន្តបានដោយមិនដឹងខ្លួនត្រូវតែមានអ្នកដទៃព្យាករ។

៣-ព្រះអរហន្តនៅមានសេចក្តីសង្ស័យក្នុងពាក្យប្រដៅរបស់ព្រះពុទ្ធ។

៤-បុគ្គលនឹងបន្លុះព្រះអរហន្ត ដោយមិនមានអាចារ្យមិនបានទេ។

៥-បុគ្គលនឹងបន្លុះព្រះអរហន្តបាន ដោយបន្លឺសម្លេងថា "ទុក្ខហ្ន៎ៗ" ។

សូមជម្រាបថា គម្ពីរភេទធម្មតិចក្កសាស្រ្តនេះ កើតឡើងក្រោយ មិនគួរកាន់យកជាប្រមាណបានទេ។ ឯមតិ ៥ ខ ទៀតសោត ជាគំនិតបំភាន់បង្វែងដាន ដើម្បីបិទបាំងកំហុសរបស់ក្រុមខ្លួន ដែលបែកចេញទៅតែប៉ុណ្ណោះ វិញ្ញូជនមិនបានទុកថាមានខ្លឹមសារអ្វីទេ។

ម៉្យាងទៀត ក្នុងគម្ពីរទីបវង្ស សម្តែងថា ពួកវជ្ជីបុត្តភិក្ខុដែលត្រូវបរាជ័យក្នុងពេលទុតិយសង្គាយនានោះ បានចេញពីក្រុងវេសាលីទៅធ្វើសង្គាយនាថ្មីមួយទៀត នៅបុប្អូនគរ "បាដលីបុត្រ" មានភិក្ខុចូលរួម ១ ម៉ឺនរូប ហើយឲ្យឈ្មោះសង្គាយនារបស់ក្រុមខ្លួនថា មហាសង្គីតិ ការធ្វើសង្គាយនាដ៏ធំ។ ពួកវជ្ជីបុត្តភិក្ខុជាអធម្មវាទី អវិនយវាទី ទាំងនោះបានតែងគម្ពីរថ្មីៗទំលាយនូវព្រះធម៌វិន័យដែលព្រះអរហន្តទាំងឡាយលោកបានចងក្រងទុកល្អហើយ។ ដោយការមិនយល់ច្បាស់នូវអត្ថ និងព្យញ្ជន នូវសេចក្តីសង្ខេប និងសេចក្តីបរិយាយ ពួកនោះបានធ្វើអត្ថាធិប្បាយថ្មីៗតាមសេចក្តីយល់ឃើញ និងការពេញចិត្តរបស់

ក្រុមខ្លួន។ នេះជាចំណុចសំខាន់ ដែលនាំឲ្យពុទ្ធសាសនាផ្នែកមហាយានចាប់កំណើតឡើង ។

## តតិយសង្គាយនា

ព្រះពុទ្ធសាសនាកន្លងទៅបាន ២១៨ ឆ្នាំ ព្រះមហាក្សត្រមួយព្រះអង្គ ព្រះនាម អសោកមហារាជ បានឡើងសោយរាជ្យនៅក្រុងបាដលីបុត្រ ដែនមគធៈ។ ព្រះមហា - ក្សត្រអង្គនេះ មានចេស្តាបារមី មានឫទ្ធានុភាពពេញជម្ពូទ្វីបទាំងឡាយ ព្រះអង្គមាន ព្រះទ័យជ្រះថ្លាយ៉ាងក្រៃលែងចំពោះព្រះពុទ្ធសាសនា បានទំនុកបម្រុងព្រះភិក្ខុសង្ឃ ដោយបច្ច័យ ៤ យ៉ាងសម្បូរហូរហៀរ គ្រប់ទិសទី ក្នុងគោលបំណងមិនឲ្យព្រះសង្ឃមាន កង្វល់អ្វីក្នុងរឿងនេះឡើយ ហើយគិតតែពីខំបដិបត្តិធម៌វិន័យឲ្យបានល្អប្រពៃតែប៉ុណ្ណោះ ប៉ុន្តែ បែរជាមានច្រកខុសធំមួយ នាំឲ្យអ្នកបួសសាសនាដទៃរាប់ម៉ឺនអង្គ ចូលមកបន្លំបួស ប្លមដើម្បីស្វែងរកលាភសក្ការៈ ហើយសម្តែងលទ្ធិរបស់ខ្លួនខុសចាកធម៌វិន័យរបស់ព្រះពុទ្ធ ទៅវិញ។ នេះជាចំណុចមួយធ្វើឲ្យព្រះពុទ្ធសាសនាសៅហ្មង នាំឲ្យព្រះសង្ឃទ្រទ្រង់ធម៌-វិន័យពិតប្រាកដមិនអាចធ្វើឧបោសថកម្មជាដើម រួមជាមួយភិក្ខុអលជ្ជីទាំងនោះបាន រហូតទាល់តែព្រះមោគ្គលីបុត្តតិស្សត្ថេរ រត់ទៅគង់នៅឯអធោគង្គបព្វតិ៍អស់ ៧ ព្រះវស្សា ។

ព្រះបាទអសោក បានឃើញព្រះសង្ឃបាក់បែកគ្នាដូចនោះ បានត្រាស់បញ្ជាឲ្យ អាមាត្យទៅរម្ងាប់អធិករណ៍សម្រុះសម្រួល បបួលព្រះសង្ឃឲ្យរួបរួមសាមគ្គីធ្វើឧបោសថ កម្មជាដើមជាមួយគ្នា[៨]។ ព្រះសង្ឃដែលទ្រទ្រង់វិន័យបរិសុទ្ធប្រកែកថា មិនអាចរួបរួម សាមគ្គីធ្វើឧបោសថជាមួយគ្នានឹងពួកភិក្ខុអលជ្ជីបួសប្លមមានសំវាសមិនស្មើគ្នាដូចនោះ បានទេ...។ អាមាត្យយល់ថា ភិក្ខុទាំងឡាយនោះប្រឆាំងនឹងព្រះរាជបញ្ជា ក៏ប្រហារជីវិត ភិក្ខុសង្ឃអស់ជាច្រើនអង្គ។ ព្រះមហាក្សត្រ បានជ្រាបរឿងនោះ ក៏រន្ធត់ព្រះទ័យយ៉ាង-ខ្លាំង មិននឹកថា នឹងមានហេតុការណ៍យ៉ាងនេះកើតឡើងដូចនេះសោះ។ ព្រះអង្គទ្រង់ ព្រះតម្រិះថា តើបាបនោះនឹងមានដល់ព្រះអង្គដែរឬយ៉ាងណា? ព្រះសង្ឃអង្គខ្លះថ្វាយ

[៨] *ផ្ទុវលោក គេចូលចិត្តបង្គាប់គ្នា ឲ្យសាមគ្គីបែបធ្មេចភ្នែក អញ្ចឹង។ សាមគ្គីជាមួយអ្នកលក់ជាតិ អ្នកលួចជាតិ អ្នកបំផ្លាញជាតិ ។ល។ ដូចសម័យយ៉ាងសព្វថ្ងៃ ពិបាកជាងអូសឫស្សីច្រាសចុងទៅទៀត មានតែជនចោលម្សៀតទេ ទើបគេងាយសាមគ្គីកើត ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនតែប៉ុណ្ណោះ។*

យោបល់ថា ព្រះអង្គអ្នកបញ្ជាអាមាត្យអ្នកធ្វើតាម ដូចនេះត្រូវតែទទួលបាបជាមួយគ្នា ព្រះសង្ឃអង្គខ្លះថា អាមាត្យត្រូវទទួលបាបច្រើនជាង ប៉ុន្តែ ព្រះអង្គអ្នកបញ្ជាក៏មានបាបខ្លះដែរ។ ព្រះសង្ឃអង្គខ្លះទៀតថា រឿងនេះត្រូវតែទៅនិមន្តព្រះមោគ្គលីបុត្តតិស្សត្ថេរមក ទើបលោកអាចវិនិច្ឆ័យថ្វាយសេចក្តីច្បាស់លាស់បាន។ ព្រះបាទអសោក បានបញ្ជាឲ្យអាមាត្យទៅនិមន្តព្រះមោគ្គលីបុត្តតិស្សត្ថេរមក... លើកទីមួយលោកមិននិមន្តមកទេ ព្រោះនិមន្តមិនត្រូវទំនង លើកទីពីរទើបលោកព្រមនិមន្តមក...។ ព្រះរាជាត្រាស់សួរ... រឿងអាមាត្យសម្លាប់ព្រះសង្ឃនោះ... តើព្រះអង្គត្រូវទទួលបាបនោះដែរឬទេ? ព្រះមោគ្គលីបុត្តតិស្សត្ថេរ ឆ្លើយថា បើព្រះអង្គមានចេតនាសម្លាប់ព្រះអង្គត្រូវតែបានបាប បើអត់មានចេតនាទេ អត់មានបាបទេ។ ព្រះរាជា ទ្រង់សប្បាយព្រះទ័យឡើងវិញ ព្រោះព្រះអង្គឥតមានចេតនា នឹងសម្លាប់ព្រះសង្ឃទេ។ បន្ទាប់មកព្រះបាទអសោកបានជួយឧបត្ថម្ភព្រះមោគ្គលីបុត្តតិស្សត្ថេរ ដើម្បីជម្រះមន្ទិលក្នុងសាសនា បានប្រមូលព្រះសង្ឃមកប្រជុំហើយសាកសួរធម៌វិន័យអង្គណាមិនចេះ ឬឆ្លើយខុសចាកពុទ្ធវចនៈ ត្រូវតែលាកចាកសិក្ខា ពេលនោះមានព្រះសង្ឃបួសប្លមត្រូវសឹកទៅវិញរាប់ម៉ឺនអង្គ។ បន្ទាប់មកទៀត ព្រះមោគ្គលីបុត្តតិស្សត្ថេរ រៀបចំធ្វើសង្គាយនាពិនិត្យផ្ទៀងផ្ទាត់ដោយក្រងធម៌វិន័យទុកជាក្បួនច្បាប់ល្អតទៅទៀត។

## គោលបំណងនៃតតិយសង្គាយនា

១-ព្រះពុទ្ធសករាជកន្លងទៅបាន ២៣៤ ឆ្នាំ[៩]។
២-ប្រជុំសន្និបាតនៅ អសោការាម ក្រុងបាដលីបុត្រ ដែនមគធៈ។
៣-ព្រះមោគ្គលីបុត្តតិស្សត្ថេរ ជាប្រធាន។
៤-ព្រះអរហន្តចូលរួមប្រជុំ ១០០០ អង្គ។
៥-គោលបំណង ដើម្បីកំចាត់ភិក្ខុអលជ្ជី និងផ្ទៀងផ្ទាត់ធម៌វិន័យ។
៦-ព្រះបាទអសោកមហារាជ ជាអ្នកឧបត្ថម្ភក៏។
៧-ប្រជុំអស់ចិរវេលា ៩ ខែ ទើបសម្រេច។

[៩] ច្បាប់ខ្លះថា ២៣៥ ឆ្នាំ ក៏មាន ២៣៦ ឆ្នាំ ក៏មាន ប៉ុន្តែក្រោយពីសោយរាជ្យ ១៦ ឆ្នាំ។

**ខសង្កេត** ដោយការប្រជុំធ្វើតតិយសង្គាយនានេះ មានរឿងសំខាន់ ២ ទៀតបានកើតឡើង គឺ៖

១-**ព្រះមោគ្គលីបុត្តតិស្សត្ថេរ** បានរចនាគម្ពីរកថាវត្ថុ អធិប្បាយសេចក្ដីឲ្យបានច្បាស់ឡើង ។

២-**ព្រះបាទអសោកមហារាជ** បានបញ្ជូនសមណទូតឲ្យចេញទៅប្រកាសផ្សាយពុទ្ធសាសនាក្នុងទីផ្សេងៗ គឺ៖

១-**ព្រះមជ្ឈន្តិកត្ថេរ** ទៅកាន់ដែន កស្មិរៈ និងគន្ធារៈ ទិសពាយព្យនៃប្រទេសឥណ្ឌា ។

២-**ព្រះមហាទេវៈ** ទៅមហិសកមណ្ឌល ខាងត្បូងទន្លេគោធវរី ខេត្តម៉ៃសោរ ។

៣-**ព្រះរក្ខិតត្ថេរ** ទៅវនវាសីជនបទ ទិសឧត្តរនៃខេត្តកន្នរៈ ។

៤-**ព្រះយោនកធម្មរក្ខិតត្ថេរ** ទៅអបរន្តជនបទ ខេត្តគុជរាត ។

៥-**ព្រះមហាធម្មរក្ខិតត្ថេរ** ទៅមហារដ្ឋជនបទ ខេត្តមរថ ។

៦-**ព្រះមហារក្ខិតត្ថេរ** ទៅយោនកប្រទេស អាណាចក្រក្រិក ។

៧-**ព្រះមជ្ឈិមត្ថេរ** ទៅហិមវន្តប្រទេស នេប៉ាល ។

៨-**ព្រះសោណត្ថេរ** និង **ព្រះឧត្តរត្ថេរ** ទៅសុវណ្ណភូមិ ។

៩-**ព្រះមហិន្ទត្ថេរ** ទៅប្រទេសលង្កា ។

សូមជម្រាបថា សង្គាយនា ដែលចរឹកទុកក្នុងគម្ពីរព្រះត្រៃបិដក មានតែ ២ លើកទេ គឺ បឋមសង្គាយនា និងទុតិយសង្គាយនា ។ សង្គាយនាទាំង ២ លើកនេះ គ្មានប្រើពាក្យថា ព្រះត្រៃបិដក៖ វិន័យបិដក សុត្តន្តបិដក អភិធម្មបិដក ទេ ប្រើតែពាក្យថា ធម៌ និងវិន័យ ដូចដែលព្រះពុទ្ធអង្គ ធ្លាប់ប្រាប់ព្រះអានន្ទថា យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ...។ ចាប់តាំងពី តតិយសង្គាយនា មកមានក្នុងគម្ពីរជាន់ក្រោយ អដ្ឋកថា អដ្ឋកថាចារ្យ សម្ដែងថា ការចាត់ជាព្រះត្រៃបិដក មានមកតាំងពីបឋមសង្គាយនាម្ល៉េះ ។

## ចតុត្ថសង្គាយនា លើកទី ១

ព្រះពុទ្ធសករាជកន្លងទៅបានប្រមាណ ៦៤៣ ឆ្នាំ ព្រះបាទកនិស្កៈ បានឧបត្ថម្ភឲ្យមានការធ្វើសង្គាយនាលើកទី ៤ នៅក្រុងជាលន្ធរៈ “កស្មិរៈ” ប្រទេសឥណ្ឌាភាគខាងជើង ដោយហេតុថាព្រះសង្ឃដែលនិមន្តទៅថ្វាយធម្មទេសនា ចេះតែមានខសេចក្ដីមិនស្របគ្នា អង្គខ្លះសំដែងអីចេះ អង្គខ្លះសំដែងអីចុះ មានពេលខ្លះខុសផ្ទុយគ្នាស្រឡះក៏មានដែរ។ សង្គាយនាលើកនេះគេថា ធ្វើជារបៀបផ្សំចូលគ្នា គឺ ថេរវាទក៏មាន មហាយានក៏មាន សូម្បីតែសាសនាព្រាហ្មណ៍ក៏មានយកទៅចូលផ្សំជាមួយដែរ។ អ្នកខ្លះទៀតគេថា មិនមែនជាសង្គាយនាទេ តែជាការប្រជុំដើម្បីជជែកគ្នាជាមួយភិក្ខុហៀនចាំង ដែលតែងគម្ពីរសរសើរពុទ្ធសាសនាផ្នែកមហាយាន[១០]។

## សង្គាយនាក្នុងប្រទេសលង្កា

កាលធ្វើតតិយសង្គាយនាស្រេចហើយ ព.ស.២៣៤ ព្រះមហិន្ទត្ថេរព្រមដោយ-ព្រះសង្ឃ ៥ អង្គ បានធ្វើដំណើរទៅផ្សាយពុទ្ធសាសនា នៅប្រទេសលង្កា ទេសនាប្រោសព្រះបាទទេវានម្បិយតិស្សៈ ព្រមទាំងប្រជាជននៅកោះនោះឲ្យជ្រះថ្លា ប្រតិស្ឋានព្រះពុទ្ធសាសនាទុកក្នុងទីនោះ។ ព.ស.២៣៨ ព្រះមហិន្ទត្ថេរ ដោយមានការឧបត្ថមពីព្រះ - -បាទទេវានម្បិយតិស្ស បានរៀបចំធ្វើសង្គាយនាជាលើកដំបូងនៅកោះសិរីលង្កា ដើម្បីព្រះពុទ្ធសាសនាឲ្យតាំងនៅមាំ មិនមែនដោយមានហេតុអ្វីមួយដែលនាំឲ្យសាសនាសៅ-ហ្មងនោះទេ។ សង្គាយនាគ្រានេះ ព្រះមហិន្ទត្ថេរ ជាប្រធាន ព្រះមហាអរិដ្ឋ សិស្សរបស់ព្រះមហិន្ទត្ថេរ ជាអ្នកវិសជ្ជនា ការកសង្ឃចូលរួម ៦៨000 អង្គ ធ្វើនៅថូបារាម ក្រុងអនុរាធបុរៈ អស់ចិរវេលា ១០ ខែ ទើបសម្រេច។ នេះជាសង្គាយនា លើកទី ៤ ផ្នែកថេរវាទ រាប់បន្តពីតតិយសង្គាយនានៅឥណ្ឌាមក[១១]។

---

[១០] *សង្គាយនាលើកទី ៤ នៅប្រទេសឥណ្ឌានេះ ពុទ្ធសាសនិកលង្កា ភូមា ថៃ ខ្មែរ និង ឡាវ មិនបានទទួលស្គាល់ទេ។ ឯផ្នែកមហាយាន គេក៏មិនទទួលស្គាល់តតិយសង្គាយនាជាដើមផ្នែកថេរវាទដែរ។ ការនាំមកជម្រាបនេះ គ្រាន់តែជាពត៌មាន។*

[១១] *ប្រទេសភូមា មិនទទួលស្គាល់សង្គាយនានេះទេ ព្រោះទើបនឹងធ្វើតតិយសង្គាយនាហើយ ពីរបីឆ្នាំប៉ុណ្ណោះ ហើយប្រទេសលង្កាក៏ទើបនឹមានពុទ្ធសាសនាថ្មីៗ ផង...។*

## បញ្ចមសង្គាយនា

ព្រះបាទវដ្តគាមណីអភ័យ ឡើងសោយរាជ្យបានបន្តិច មានគេមកដណ្តើមរាជ្យ ព្រះអង្គបានគេចរត់ទៅពួនលាក់ខ្លួនក្នុងទីផ្សេងៗ អស់ ១៤ ឆ្នាំ ពេលនោះ បាន ព្រះតិស្សត្ថេរ ជាអ្នកឧបត្ថមក៏។ លុះបានឡើងសោយរាជ្យពិតប្រាកដ ព្រះអង្គនឹកដល់គុណូបការនោះ ទើបចាត់ឲ្យសាងវត្តមួយឈ្មោះ អភ័យគីរីវិហារ ប្រគេនព្រះតិស្សត្ថេរ ។ ពេលនោះ ព្រះសង្ឃលង្កាបែកជា ២ ពួក គឺ មហាវិហារ និង អភ័យគីរីវិហារ បដិបត្តិច្របូកច្របល់នឹងគ្រហស្ថច្រើនពេក នេះជាហេតុមួយ។ ហេតុមួយទៀត ព្រះសង្ឃយល់ឃើញថា ការរក្សាពុទ្ធវចនៈ ព្រះត្រៃបិដក ដោយវិធីទន្ទេញចាំមាត់តគ្នា "មុខបាឋ" ទៅអនាគត អាចមានការភ្លាំងភ្លាត់ ដូចនេះត្រូវតែចារឹកជាលាយលក្ខណ៍អក្សរទុកក្នុងស្លឹករឹត ទើបគង់វង្សស្ថិតស្ថេរចិរកាលបាន។ ដោយប្រារព្ធហេតុទាំងពីរនេះ ព្រះសង្ឃបានថ្វាយសេចក្តីដល់ព្រះបាទវដ្តគាមីអភ័យ ព្រះអង្គមានព្រះទ័យសោមនស្ស បានឲ្យរៀបចំកសាងមណ្ឌបធ្វើកន្លែងប្រជុំសង្គាយនានៅវត្តមហាវិហារ។ នេះជាសង្គាយនាលើកទី ២ នៅប្រទេសសិរីលង្កា[១២]។

## គោលសំខាន់នៃបញ្ចមសង្គាយនា

១-ព្រះពុទ្ធសករាជកន្លងទៅ ៤៣៣ ឆ្នាំ[១៣]។
២-ព្រះពុទ្ធទត្តត្ថេរ ជាប្រធាន អ្នកសួរ ព្រះតិស្សត្ថេរ[១៤] ជាអ្នកវិសជ្ជនា។
៣-ព្រះសង្ឃចូលរួមប្រជុំ ១០០០ អង្គ ។
៤-ធ្វើនៅវត្តមហាវិហារ។
៥-ព្រះបាទវដ្តគាមណីអភ័យ ជាអ្នកឧបត្ថម្ភក៏។
៦-អស់ចិរវេលា ១ ឆ្នាំ ទើបសម្រេច។
៧-ប្រារព្ធរឿងព្រះសង្ឃច្របូកច្របល់នឹងគ្រហស្ថ និងការចារឹកពុទ្ធវចនៈព្រះត្រៃបិដកជាលាយលក្ខណ៍អក្សរទុកក្នុងស្លឹករឹតដំបូងបង្អស់ក្នុងប្រវត្តិពុទ្ធសាសនា។

[១២] *ភូមាទទួលស្គាល់សង្គាយនានេះ ប៉ុន្តែ រាប់ថាជាលើកទី ៤ បន្ទាប់ពីតតិយសង្គាយនានៅឥណ្ឌាមក។*
[១៣] *អ្នកខ្វះថា ៤៥០ ឆ្នាំ អ្នកខ្វះថា ៥២០ ឆ្នាំ ដូចនេះក៏មាន។*
[១៤]

ក្រៅពីនេះ នៅព.ស.២៤០៩ សិរីលង្កាមានធ្វើសង្គាយនាម្តងទៀត នៅរតនបុរៈ មានព្រះហិក្ខុទុវេ សិរីសុមង្គល ជាប្រធាន ធ្វើ ៥ ខែ ទើបសម្រេច។ នេះជាសង្គាយនាលើកទី ៣ នៅសិរីលង្កា សង្គាយនាលើកនេះ ក្រៅពីលង្កាខ្លួនឯង គ្មាននរណាទទួលស្គាល់ទេ។

## សង្គាយនានៅប្រទេសភូមា

សង្គាយនាលើកដំបូងនៅប្រទេសភូមា ភូមាហៅថា បញ្ចមសង្គាយនា[១៥] គឺសង្គាយនាលើកទី ៥ ។ សង្គាយនានេះកើតឡើងក្នុងព.ស.២៤១៤ ដោយការឧបត្ថម្ភរបស់ព្រះបាទមិនដុងនៃប្រទេសភូមា។ ព្រះថេរៈ ៣ ព្រះអង្គគឺ ព្រះជាគរាភិវង្ស ព្រះនរិន្ទាធជ ព្រះសុមង្គលសាមី ផ្លាស់ប្តូរវេនបន្តគ្នាធ្វើប្រធានដោយលំដាប់ មានព្រះថេរៈចេះចាំស្ទាត់ក្នុងព្រះត្រៃបិដក ចំនួន ២៤០០ អង្គ ចូលរួមប្រជុំនៅទីក្រុងមណ្ឌលេ ធ្វើ ៥ ខែ ទើបសម្រេច។ សង្គាយនាលើកនេះ មានចារឹកពុទ្ធវចនៈ ព្រះត្រៃបិដកលើផែនថ្មើមថ្មចំនួន ៧២៩ ផ្ទាំង តម្កល់ទុកជាឯកសារផង។

សង្គាយនាលើកទី ២ នៅភូមា ភូមាហៅថា ឆដ្ឋសង្គាយនា គឺសង្គាយនាលើកទី ៦ ។ សង្គាយនានេះ កើតឡើងក្នុងព.ស.២៤៩៨ ចប់ក្នុង ព.ស.២៥០០ ធ្វើបុណ្យឆ្លងពាក់កណ្តាលសាសនាតែម្តង។ ក្នុងការធ្វើសង្គាយនាលើកនេះ ភូមាបាននិមន្តព្រះសង្ឃថេរវាទ ភូមា លង្កា ថៃ ខ្មែរ និងឡាវ ចូលរួមផង។ **សម្តេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ** ក៏បានស្តេចយាងជាអធិបតីក្នុងពិធីនោះដែរ។ គោលបំណងនៃសង្គាយនានេះ គឺដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងបោះពុម្ពបាលី អដ្ឋកថា ចែកចាយផ្សព្វផ្សាយទូទៅក្នុងប្រទេសផ្សេងៗ រួមទាំងប្រទេសកម្ពុជាយើងផងដែរ។

## សង្គាយនានៅប្រទេសថៃ

*ការរាប់សង្គាយនាប្រទេសថៃ មានដូចតទៅនេះ៖*

សង្គាយនាទី ១-២-៣ ធ្វើនៅប្រទេសឥណ្ឌា។ ថៃមិនរាប់សង្គាយនាទី ៤ នៅឥណ្ឌាទេ។

---

១៥

សង្គាយនាទី ៤-៥ ធ្វើនៅលង្កា។ ភូមាមិនរាប់សង្គាយនាទី ១ នៅលង្កា តែថៃព្រម រាប់ហើយយកមករៀបលំដាប់ជាទី ៤ បន្តពីឥណ្ឌាមក ឯសង្គាយនាទី ៣ នៅលង្កា ភូមា និងថៃ មិនរាប់ដូចគ្នា។

សង្គាយនាទី ៦ នៅលង្កា កាលព.ស.៩៥៦ ព្រះពុទ្ធឃោសៈ បានប្រែ និងរៀបរៀង អដ្ឋកថា ពីភាសាលង្កាមកជាភាសាបាលី ក្នុងសម័យព្រះមហានាម។ ការប្រែ និងរៀប-រៀងនេះ លង្កាខ្លួនឯង មិនរាប់ថាជាសង្គាយនាទេ តែថៃត្រឡប់ជារាប់ថាជាសង្គាយនាទី ៦ ទៅវិញ។ ឯសង្គាយនាទី ៥-៦ របស់ភូមា ថៃមិនរាប់យកផងទេ។

សង្គាយនាទី ៧ ធ្វើនៅលង្កា កាលព.ស.១៥៨៧ ព្រះកស្សបត្ថេរ ជាប្រធាន មាន ព្រះថេរៈចូលរួមជាង ១០០០ អង្គ បាននាំគ្នារចនា ដីកា គឺ អត្ថាធិប្បាយអដ្ឋកថា។ តែលង្កា ខ្លួនឯងមិនរាប់ថាជាសង្គាយនាទេ។

សង្គាយនាទី ៨ ធ្វើនៅប្រទេសថៃ ប្រមាណព.ស.២០២០ ព្រះបាទតិលោករាជនៃ ឈៀងម៉ៃ បាននិមន្តព្រះភិក្ខុសង្ឃដែលចេះចាំស្ទាត់ព្រះត្រៃបិដកច្រើនរយអង្គ មកជួយ ពិនិត្យផ្ទៀងផ្ទាត់ជម្រះគម្ពីរព្រះត្រៃបិដក នៅវត្តពោធារាម អស់ចិរវេលា ១ ឆ្នាំ ទើប សម្រេច នេះរាប់ថាជាសង្គាយនាទី ១ ក្នុងប្រទេសថៃ។

សង្គាយនាទី ៩ ធ្វើនៅប្រទេសថៃ កាលព.ស.២៣៣១ ព្រះបាទសម្តេចព្រះពុទ្ធយ៉ត ហ្វាចុឡាលោក បឋមក្សត្រនៃបរមរាជចក្រីវង្ស ក្រុងរតនកោសិន្ទ៍ បាំងកក បាននិមន្ត ព្រះសង្ឃ ២១៨ អង្គ និងបណ្ឌិតាចារ្យ ៣២ នាក់ ឲ្យជួយពិនិត្យផ្ទៀងផ្ទាត់ជម្រះគម្ពីរ-ព្រះត្រៃបិដក ហើយចារឹកទុកក្នុងស្លឹករឹត ប្រជុំគ្នាធ្វើអស់ចិរវេលា ៥ ខែ ទើបសម្រេច នេះរាប់ថាជាសង្គាយនាទី ២ ក្នុងប្រទេសថៃ។

## សង្គាយនានៅប្រទេសកម្ពុជា

នៅប្រទេសកម្ពុជាយើង តាំងពីព្រេងនាយមកមិនមានប្រវត្តិស្ថិទុកថា បានធ្វើ សង្គាយនាព្រះត្រៃបិដកទេ។ ក្នុងរជ្ជកាលនៃព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ចមចក្រពង្ស ព្រះចៅក្រុងកម្ពុជាធិបតី ទើបមានការចាប់ផ្តើមធ្វើសង្គាយនាព្រះត្រៃបិដក នេះឡើងជាលើកដំបូង។ ការពិនិត្យផ្ទៀងផ្ទាត់ និងប្រែគម្ពីរព្រះត្រៃបិដកនេះ ចាប់ផ្តើម នៅថ្ងៃ ៣ កើត ខែបុស្ស ឆ្នាំមមី ទោស័ក ព.ស.២៤៧២ ត្រូវនឹងថ្ងៃទី ២ មករា ១៩៣០[១៦]

---

[១៦] *វិនយបិដក មហាវគ្គ ភាគ ១ ទំព័រ xi ។*

មកដល់ ព.ស.២៥០០ អស់រយៈវេលា ២៨ ឆ្នាំ ចប់សព្វគ្រប់បរិបូណ៌ ប៉ុន្តែ ការបោះពុម្ពបានត្រឹមតែចំនួន ៥០ ភាគ គឺ វិនយបិដក ១៣ ភាគ សុត្តន្តបិដក ៣៧ ភាគ នៅសល់ខាន ៦០ ភាគទៀត មកដល់ ព.ស.២៥១២ ទើបបោះពុម្ពចប់ស្រេច គិតទៅអស់រយៈវេលា ៤០ ឆ្នាំគត់។ ការធ្វើសង្គាយនាលើកនេះ បានចារឹកទុកក្នុងគម្ពីរព្រះត្រៃបិដកខ្មែរយើងថា ឧត្តមសង្គីតិ[១៧] ប្រែថា ការសង្គាយនាដ៏ប្រសើរបំផុត។ ការសង្គាយនាលើកនេះ មានលក្ខណៈពិសេស ២ យ៉ាងគឺ ១-ទំព័រម្ខាងជាបាលី ទំព័រម្ខាងទៀតជាសេចក្តីប្រែ ២-ការប្រែសម្រាយនេះ ប្រទេសកម្ពុជាយើងបានធ្វើចប់មុនគេបង្អស់ក្នុងពិភពលោក គ្រាន់តែមានការយឺតយូរក្នុងរឿងបោះពុម្ពបន្តិច ព្រោះប្រទេសយើងមានការខ្វះខាតច្រើន។ ចំណែកឯប្រទេសឡាវ ជាប្រទេសកាន់ពុទ្ធសាសនាថេរវាទដូចយើងដែរ មិនឃើញមានឯកសារអ្វីស្តីបញ្ជាក់ថាមានធ្វើសង្គាយនាទេ។

## សង្គាយនាយជាហេតុឱ្យកើតគម្ពីរព្រះត្រៃបិដក

ក្នុងសម័យពុទ្ធកាល មិនទាន់មានចាត់ពុទ្ធវចនៈជាគម្ពីរព្រះត្រៃបិដក គឺ ព្រះវិន័យបិដក ព្រះសុត្តន្តបិដក ព្រះអភិធម្មបិដក ដូចនេះទេ ប្រើត្រឹមតែពាក្យថា ធម៌ និង វិន័យប៉ុណ្ណោះ[១៨]។ សូម្បីសម័យបឋមសង្គាយនា និងទុតិយសង្គាយនា ក៏នៅប្រើពាក្យ ធម៌ និងវិន័យនេះដដែល។ ចាប់តាំងពី តតិយសង្គាយនា មកប្រើពាក្យថា ព្រះត្រៃបិដក “តិបិដក ឬ តេបិដក” ហើយ ប៉ុន្តែ ដែលជាក់ច្បាស់មែនទែនគឺ បញ្ចមសង្គាយនានៅប្រទេសសិរីលង្កា ដែលចាប់មានចារឹកទុកក្នុងសាស្ត្រស្លឹករឹត ជាភ័ស្តុតាងមកនោះឯង។

[១៧] *អ្នកខ្លះហៅថា ឆដ្ឋសង្គាយនា ប៉ុន្តែ មិនដឹងជារាប់យកណា ចោលណាទេ ។*

[១៨] *ក្នុងសម័យពុទ្ធកាល ពាក្យថា បិដក មានហើយ ប៉ុន្តែ មិនសំដៅយកការចែកជាវិន័យបិដក សុត្តន្តបិដក អភិធម្មបិដក ដូចសព្វថ្ងៃនេះទេ សំដៅយកសេចក្តីត្រឹមតែគម្ពីរប៉ុណ្ណោះ ដូចមានក្នុងកាលាមសូត្រថា មា បិដកសម្បទានេន កុំប្រកាន់ជឿដោយគ្រាន់តែឃើញមានសេចក្តីសរសេរទុកក្នុងគម្ពីរ ក្បួន តម្រា។*

## ព្រះត្រៃបិដកគឺអ្វី

គ្រប់សាសនាធំៗ ទាំងអស់សុទ្ធតែមានគម្ពីរសម្រាប់សាសនារៀងៗខ្លួន។ សាសនាព្រាហ្មណ៍ មានគម្ពីរវេទ សាសនាគ្រិស្ត មានគម្ពីរប៊ីប សាសនាឥស្លាម មានគម្ពីរកុរអាន។ ឯព្រះពុទ្ធសាសនារបស់យើង មានគម្ពីរព្រះត្រៃបិដក។ ព្រះត្រៃបិដក ជាគម្ពីរដើមជាងគេបំផុត ធំជាងគេបំផុត សំខាន់ជាងគេបំផុតក្នុងព្រះពុទ្ធសាសនា។ **ព្រះ** ជាពាក្យគោរព លើកតម្កើង **ត្រៃ** ប្រែថា បី **បិដក** ប្រែថាគម្ពីរ ក្បួន តម្រា ភាជនៈ ឬកញ្ចើ។ បើប្រែថា ភាជនៈ ឬកញ្ចើ សំដៅសេចក្ដីថា ភាជនៈ ឬកញ្ចើ សម្រាប់ដាក់ពុទ្ធវចនៈពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ។ ដូចបានជម្រាបមកខាងដើមស្រាប់ហើយ ក្នុងពេលដែលព្រះពុទ្ធគង់ព្រះជន្មនៅ ពាក្យប្រៀនប្រដៅរបស់ព្រះអង្គ លោកហៅថា ព្រះធម៌ និងព្រះវិន័យ តែប៉ុណ្ណោះ ប៉ុន្តែក្រោយមក ដោយសារតែមានធ្វើសង្គាយនា ទើបលោកចែកជាព្រះត្រៃបិដក គឺ **ព្រះវិន័យបិដក ព្រះសុត្តន្តបិដក ព្រះអភិធម្មបិដក**។

## វិនយបិដក

**វិនយបិដក** ជាគម្ពីរស្ដីពីច្បាប់ក្រិត្យក្រម សម្រាប់ភិក្ខុ ភិក្ខុនី បដិបត្តិ[១៩] គម្ពីរវិនយនេះ មានសេចក្ដីពិស្ដារណាស់ បើចែកជាគម្ពីរ មាន ៥ គម្ពីរគឺៈ

១-**អា** ៖ **មហាវិភង្គ** ពោលដោយសីលរបស់ភិក្ខុដែលមានក្នុងបាតិមោក្ខ តាំងពីបារាជិក រហូតដល់ សេក្ខិយាវត្ត។

២-**ភា** ៖ **ភិក្ខុនីវិភង្គ** ពោលដោយសីលរបស់នាងភិក្ខុនីចាប់តាំងពីបារាជិក រហូតដល់អធិករណសមថៈ។

៣-**ម** ៖ **មហាវគ្គ** វគ្គធំ បែងជាខន្ធកៈ មាន ១០ គឺ ១-មហាខន្ធកៈ ២-ឧបោសថក្ខន្ធកៈ ៣-វស្សុបនាយិកក្ខន្ធកៈ ៤-បវារណាក្ខន្ធកៈ ៥-ចម្មក្ខន្ធកៈ ៦-ភេសជ្ជក្ខន្ធកៈ ៧-កឋិនក្ខន្ធកៈ ៨-ចីវរក្ខន្ធកៈ ៩-ចម្បេយ្យក្ខន្ធកៈ ១០-កោសម្ពិកក្ខន្ធកៈ។

៤-**ចុ** ៖ **ចុល្លវគ្គ** វគ្គតូច បែងជាខន្ធកៈ មាន ១២ គឺ ១-កម្មក្ខន្ធកៈ ២-បរិវាសិកក្ខន្ធកៈ ៣-សមុច្ចយក្ខន្ធកៈ ៤-សមថក្ខន្ធកៈ ៥-ខុទ្ទកវត្ថុក្ខន្ធកៈ ៦-សេនាសនក្ខន្ធកៈ ៧-សង្ឃភេទក្ខន្ធកៈ

[១៩] *កុំច្រឡំ មិនមែនវិន័យសម្រាប់ឧបាសក ឧបាសិកាផងទេ។ វិន័យរបស់ឧបាសក ឧបាសិកា មានក្នុងព្រះសូត្រឯណោះៗ ម៉្យាងទៀត ក្នុងវិន័យមិនមែនមានតែវិន័យទេ ធម្មចក្កប្បវត្តនសូត្រ អនត្តលក្ខណសូត្រ អាទិត្តបរិយាយសូត្រ ក៏មានក្នុងគម្ពីរព្រះវិន័យនោះដែរ។*

៨-វត្តក្ខន្ធកៈ ៩-បាតិមោក្ខដ្ឋបនក្ខន្ធកៈ ១០-ភិក្ខុនីខន្ធកៈ ១១-បញ្ចសតិកក្ខន្ធកៈ ១២-សត្តសតិកក្ខន្ធកៈ។

**៥-ប** ៖ បរិវារ[២០] បទវាយរង រួមសេចក្ដីវិនិច្ឆ័យបញ្ហាក្នុង ៤ រឿងខាងដើម។

**វិនយបិដក** រួមទាំងអស់មាន ១៣ ភាគ ចាប់ពីភាគ ១ រហូតដល់ភាគ ១៣ ។

## សុត្តន្តបិដក

**សុត្តន្តបិដក** ជាគម្ពីរស្ដីពី ធម្មទេសនា ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងប្រោសសត្វ មានប្រវត្តិ ហេតុការណ៍ និងបុគ្គលប្រកបផ្សំផង។ សុត្តន្តបិដកនេះ បែងចែកជាគម្ពីរមាន ៥ គឺ **ទី. ម. សំ. អំ. ខុ.** ។

១-**ទី.** ៖ **ទីឃនិកាយ** ពួកព្រះសូត្រខ្នាតវែង ទាំងអស់មាន ៣៤ សូត្រ។

២-**ម.** ៖ **មជ្ឈិមនិកាយ** ពួកព្រះសូត្រខ្នាតកណ្ដាល ទាំងអស់មាន ១៥២ សូត្រ។

៣-**សំ.** ៖ **សំយុត្តនិកាយ** ពួកព្រះសូត្រដែលមានប្រភេទជាមួយគ្នារួមជាក្រុមៗ រឿងឥន្ទ្រិយសំយុត្ត រឿងមគ្គ ហៅថា ហៅថា មគ្គសំយុត្ត... ទាំងអស់មាន ៧៧៦២ សូត្រ។

៤-**អំ.** ៖ **អង្គុត្តរនិកាយ** ពួកព្រះសូត្រ ដែលមានគោលធម៌ជាពួកជាក្រុម ដូចជា ឯកនិបាត ពួកធម៌ ១ ទុកនិបាត ពួកធម៌ ២.... ទាំងអស់មាន ៩៥៥៧ សូត្រ។

៥-**ខុ.** ៖ **ខុទ្ទកនិកាយ** ពួកព្រះសូត្រតូចៗ មិនចាត់ចូលក្នុង ៤ ពួកខាងដើមទេ បែងចែកជាគោលធំៗ មាន ១៥ រឿង គឺ៖

១-**ខុទ្ទកបាឋ** ព្រះសូត្រខ្លីៗ មង្គលសូត្រ រតនសូត្រ ករណីយមេត្តសូត្រ តិរោកុឌ្ឌកណ្ឌ និធិកណ្ឌ។

២-**ធម្មបទ** បទធម៌ចំនួន ៣០២ គាថា ។

៣-**ឧទាន ធម្មភាសិត** ដែលបន្លឺដោយក្ដីរីករាយ។

៤-**សុត្តនិបាត** ប្រមូលរួមព្រះសូត្ររាយរងទុកជាមួយគ្នាជាច្រើន។

៥-**វិមានវត្ថុ** រឿងទេវតាប្រាប់ហេតុដែលនាំឲ្យបានវិមាន។

---

[២០] *បុរាណាចារ្យថា វិនយបិដក មាន ៥ គម្ពីរ គឺ អា. បា. ម. ចុ. ប. ។ អា គឺ អាទិកម្ម ការធ្វើជាដើមបញ្ញត្ត តាំងពីអាបត្តិបារាជិក ដល់សង្ឃាទិសេស។ បា. គឺ បាចិត្តិយ អាបត្តិរងពីសង្ឃាទិសេសចុះមក។ ជាអក្សរកាត់ទាំងពីរ អា. បា. មិនត្រូវតាមឈ្មោះក្នុងគម្ពីរទេ ឯបីទៀតត្រឹមត្រូវហើយ ។*

៦-**បេតវត្ថុ** រឿងប្រេត។

៧-**ថេរគាថា** គាថារបស់ព្រះថេរៈ។

៨-**ថេរីគាថា** គាថារបស់ព្រះថេរី។

៩-**ជាតក** រឿងនិទានផ្សេងៗ។

១០-**និទ្ទេស** ពាក្យអធិប្បាយពន្យល់ពុទ្ធភាសិតក្នុងសុត្តនិបាត។

១១-**បដិសម្ភិទាមគ្គ** ផ្លូវនៃបញ្ញាចាក់ធ្លុះ។

១២-**អបទាន** ការពោលអាងរបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះថេរៈទាំងឡាយ។

១៣-**ពុទ្ធវង្ស** ប្រវត្តិព្រះពុទ្ធ ២៤ ព្រះអង្គ រួមទាំងព្រះសមណគោតមផង ត្រូវជា ២៥ អង្គ។

១៤-**ចរិយាបិដក** ការបំពេញបារមីរបស់ព្រះពុទ្ធមានទានបារមី សីលបារមី ជាដើម។

**សុត្តន្តបិដក** ទាំងអស់មានចំនួន ៦៣ ភាគ ចាប់ពីភាគ ១៤ រហូតដល់ភាគ ៧៦ ។

## អភិធម្មបិដក

**អភិធម្មបិដក** ជាគម្ពីរស្ដីពីធម៌អាថ៌ជ្រាលជ្រៅល្អិតសុខុម ជាសាច់ធម៌សុទ្ធៗ មិនមានប្រវត្តិ ហេតុការណ៍ និងបុគ្គល ប្រកបផ្សំផងទេ។ អភិធម្មបិដក ចែកជាគម្ពីរមាន ៧ គឺ ៖ **សំ. វិ. ធា. បុ. ក. យ. ប.** ។

១-**សំ** ៖ **សង្គណី** ការចាត់របៀបធម៌ចូលជាពួកៗ មិនឲ្យលើសពី ៣ យ៉ាង។

២-**វិ** ៖ **វិភង្គ** ការចែករំលែកធម៌ឲ្យល្អិតជា ខ ៗ ។

៣-**ធា** ៖ **ធាតុកថា** ការចាត់ធម៌ជាប្រភេទចូលគ្នាបានដោយធាតុ។

៤-**បុ** ៖ **បុគ្គលបញ្ញត្តិ** ពោលដោយបញ្ញត្តិ ៦ មានខន្ធប្បញ្ញត្តិ ជាដើម។

៥-**ក** ៖ **កថាវត្ថុ** ពោលដោយសំណួរ និងចម្លើយធម៌ផ្សេងៗ ។

៦-**យ** ៖ **យមក** ពោលដោយធម៌ជាគូៗ ។

៧-**ប** ៖ **បដ្ឋាន** ពោលដោយធម៌ជាបច្ច័យគាំទ្រគ្នា ២៤ ប្រការ។

**អភិធម្មបិដក** ទាំងអស់មានចំនួន ៣៤ ភាគ តាំងពីភាគ ៧៧ រហូតដល់ភាគ ១១០ ។

## លំដាប់ថ្នាក់នៃគម្ពីរពុទ្ធសាសនា

១-ព្រះត្រៃបិដក ជាគោលចារឹកថ្នាក់ទី ១ ហៅថា បាលី។

២-ពាក្យអធិប្បាយព្រះត្រៃបិដក ជាគោលចារឹកថ្នាក់ទី ២ ហៅថា អដ្ឋកថា ឬ វណ្ណា។

៣-ពាក្យអធិប្បាយអដ្ឋកថា ជាគោលចារឹកថ្នាក់ទី ៣ ហៅថា ដីកា។

៤-ពាក្យអធិប្បាយដីកា ជាគោលចារឹកថ្នាក់ទី ៤ ហៅថា អនុដីកា។

**ព្រះត្រៃបិដក** បានចារឹក ជាលាយលក្ខណ៏អក្សរ ក្នុងពុទ្ធសករាជកន្លងទៅបាន ៤៣៣ ឆ្នាំ ។ អដ្ឋកថា តែងឡើងក្នុងពុទ្ធសករាជកន្លងទៅបាន ៩៥៦ ឆ្នាំ។ ដីកា តែងឡើងក្នុងពុទ្ធសករាជកន្លងទៅបាន ១៥៨៧ ឆ្នាំ។ ឯអនុដីកា តែងឡើងជាបន្តបន្ទាប់មកទៀតទាំងអស់នេះហៅថា គម្ពីរ។ ឯសៀវភៅដែលគេយើងដកស្រង់ អត្ថាធិប្បាយ ចែកចាយគ្នារៀនសូធ្យបន្តិបន្តួចសព្វថ្ងៃនេះ មិនហៅថា គម្ពីរទេ ហៅត្រឹមតែសៀវភៅប៉ុណ្ណោះ។

## ត្រូវបដិបត្តិចំពោះព្រះត្រៃបិដកដូចម្ដេច

**ព្រះត្រៃបិដក** ទុកដូចជាចំការមួយដ៏ធំ ដែលសម្បូណ៌ដោយបន្លែ និងផ្លែឈើគ្រប់មុខ។ អ្នកបរិភោគ ត្រូវឆ្លាត ត្រូវស្គាល់ខ្លួនឯង ត្រូវស្គាល់បន្លែ និងផ្លែឈើ ហើយចេះជ្រើសរើសយកតែបន្លែណាឬផ្លែឈើណាដែលត្រូវនឹងសុខភាពរបស់ខ្លួនមកបរិភោគ ដោយមិនចាំបាច់យកទាំងអស់ទេ។ ការមិនព្រមបរិភោគ ឬការជ្រើសរើសខុស មិនមែនជាកំហុសអ្នកម្ចាស់ចំការទេ។

ព្រះត្រៃបិដក ជាគម្ពីរខំខាន់ជាងគេបំផុត គម្ពីរឯទៀតត្រូវតែស្របគ្នានឹងគម្ពីរព្រះត្រៃបិដក បើមានទំនាស់ ត្រូវទុកជាមិនបានការ។ ព្រះត្រៃបិដក ដូចជាច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់ ក្រឹត្យក្រុមឯទៀត ត្រូវតែស្របនឹងច្បាប់រដ្ឋធម្មនុញ្ញ បើមានទំនាស់ត្រូវទុកជាមោឃៈ។

ពិតមែនតែគម្ពីរព្រះត្រៃបិដក ជាគោលសំខាន់ជាងបំផុតយើងទាំងអស់គ្នាត្រូវតែគោរពបដិបត្តិតាមគម្ពីរព្រះត្រៃបិដកនោះយ៉ាងណាក៏ដោយ យើងក៏ត្រូវតែប្រើសទ្ធា ប្ញូក នឹងបញ្ញា ជាដរាបដែរ មិនត្រូវធ្មេចភ្នែកជឿយ៉ាងងងិតងងល់ទេ ព្រះអង្គបានហាមប្រាម មិនឲ្យប្រើជំនឿរបៀបនោះទេ ដែលមានចែងទុកក្នុងកាលាមសូត្រស្រាប់។

# កាលាមសូត្រ [២១]

ពួកកាលាមៈ ក្នុងកេសបុត្តនិគម បានក្រាបបង្គំទូលសួរព្រះសម្មាសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចំរើន សមណព្រាហ្មណ៍មួយពួកចូលមកកាន់កេសបុត្តនិគម និយាយលើកតម្កើងលទ្ធិសាសនារបស់ខ្លួន ហើយបន្តុះបង្អាប់លទ្ធិសាសនារបស់ពួកសមណព្រាហ្មណ៍ដទៃ។ មានសមណព្រាហ្មណ៍មួយពួកទៀត ចូលមកកាន់កេសបុត្តនិគមដែរ ហើយចាប់តាំងនិយាយ លើកតម្កើងលទ្ធិសាសនារបស់ខ្លួន ហើយបន្តុះបង្អាប់លទ្ធិសាសនារបស់ពួកសមណព្រាហ្មណ៍ដទៃទៀតដែរ។ បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំមានសេចក្ដីងឿងឆ្ងល់ណាស់ ចុះបណ្ដាពួកសមណព្រាហ្មណ៍ពួកណា និយាយពិត សមណព្រាហ្មណ៍ពួកណានិយាយកុហក។

ព្រះសម្មាសម្ពុទ្ធត្រាស់ថា ម្នាលកាលាមៈ អ្នកត្រូវពិនិត្យពិចារណាឲ្យជាក់ច្បាស់ដោយបញ្ញារបស់ខ្លួនថែមទៀតសិន តាមគោលដូចតទៅនេះ ៖

១-**មា អនុស្សវេន** កុំប្រកាន់ជឿ ដោយគ្រាន់តែបានឮដំណឹងតៗ គ្នា “គេកំពុងភ្ញាក់ផ្អើលតាមពាក្យឮតៗគ្នា” ។

២-**មា បរម្បរាយ** កុំប្រកាន់ជឿ ដោយគ្រាន់តែបានឃើញគេធ្វើតៗ គ្នា “គេធ្លាប់ធ្វើជាប្រពៃណីយូរយារមកហើយ”។

៣-**មា ឥតិកិរាយ** កុំប្រកាន់ជឿ ដោយគ្រាន់តែបានឮគេដំណាលតៗ គ្នាមកថាដូចនេះ “រឿងព្រេង រឿងប្រតិដ្ឋ” ។

៤-**មា បិដកសម្បទានេន** កុំប្រជឿ ដោយគ្រាន់តែឃើញមានសរសេរទុកក្នុងក្បួនតម្រា។

៥-**មា តក្កហេតុ** កុំប្រជឿ ដោយគ្រាន់តែឃើញ សមហេតុសមផល ឬត្រូវតាមតក្កវិជ្ជា។

៦-**មា នយហេតុ** កុំប្រជឿ ដោយការកាត់តំរូវផ្សេងៗ ឬ ត្រូវតាមទស្សនវិជ្ជា។

៧-**មា អាការបរិវិតក្កេន** កុំប្រជឿ ដោយគ្រាន់តែការត្រិះរិះនូវអាការ “គិតថាវាអញ្ចឹងហើយ” ។

---

[២១] *សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត ៤១/២១៦ ។*

៨-**មា ទិដ្ឋិនិជ្ឈានក្ខន្តិយា** កុំប្រជឿ ដោយគ្រាន់តែឃើញថា សមស្របនឹងការយល់ឃើញរបស់ខ្លួនហើយ។

៩-**មា ភព្វរូបតាយ** កុំប្រជឿ ដោយគ្រាន់តែឃើញថា មានសភាពគួរឲ្យជឿបាន។

១០-**មា សមណោ នោ គរុ** កុំប្រជឿ ដោយគ្រាន់តែអ្នកនិយាយនោះជាសមណៈជាគ្រូរបស់ខ្លួន។

ពួកកាលាមៈ បានស្តាប់ព្រះធម្មទេសនានេះហើយ មានសេចក្តីជ្រះថ្លា បានប្រគល់កាយថ្វាយខ្លួន ជាឧបាសក ឧបាសិកា រហូតដល់អស់ជីវិត។

## ហេតុដែលនាំឱ្យសាសនាសាបសូន្យ

សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងព្រៃឫស្សីជិតក្រុងកិមិលា។ គ្រានោះ ព្រះកិមិលៈ បានចូលទៅគាល់ហើយក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ហេតុដូចម្តេចបច្ច័យដូចម្តេច កាលដែលព្រះតថាគតបរិនិព្វានទៅហើយ ព្រះសទ្ធម្មមិនប្រតិស្ឋាននៅយូរបាន។ ព្រះមានព្រះភាគត្រាស់ថា ម្នាលកិមិលៈ កាលដែលព្រះតថាគតបរិនិព្វានទៅហើយ ព្រះសទ្ធម្មមិនប្រតិស្ឋាននៅយូរបានព្រោះ៖

១-**ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា** ក្នុងសាសនានេះមិនគោរព មិនគោតក្រែងក្នុងព្រះសាស្តា។

២-**ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា** ក្នុងសាសនានេះមិនគោរព មិនគោតក្រែងក្នុងព្រះធម៌។

៣-**ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា** ក្នុងសាសនានេះមិនគោរព មិនគោតក្រែងក្នុងព្រះសង្ឃ។

៤-**ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា** ក្នុងសាសនានេះមិនគោរព មិនគោតក្រែងក្នុងសិក្ខា។

៥-**ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា** ក្នុងសាសនានេះមិនគោរព មិនគោតក្រែងនូវគ្នានឹងគ្នា។

## ហេតុដែលនាំឱ្យសាសនាប្រតិស្ឋាននៅយូរ

ព្រះកិមិលៈ ក្រាបបង្គំទូលសួរតទៅទៀតថា បពិត្រព្រះអង្គដ៏ចំរើន ហេតុដូចម្តេច បច្ច័យដូចម្តេច កាលដែលព្រះតថាគតបរិនិព្វានទៅហើយ ព្រះសទ្ធម្ម ប្រតិស្ឋាននៅយូរបាន។ ព្រះមានព្រះភាគត្រាស់ថា ម្នាលកិមិលៈ កាលដែលព្រះតថាគតបរិនិព្វានទៅហើយ ព្រះសទ្ធម្ម ប្រតិស្ឋាននៅយូរបានព្រោះៈ

១-**ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា** ក្នុងសាសនានេះមានសេចក្តីគោរព គោតក្រែងក្នុងព្រះសាស្តា។

២-**ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា** ក្នុងសាសនានេះមានសេចក្តីគោរព គោតក្រែងក្នុងព្រះធម៌។

៣-**ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា** ក្នុងសាសនានេះមានសេចក្តីគោរព គោតក្រែងក្នុងព្រះសង្ឃ។

៤-**ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា** ក្នុងសាសនានេះមានសេចក្តីគោរព គោតក្រែងក្នុងសិក្ខា។

៥-**ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា** ក្នុងសាសនានេះមានសេចក្តីគោរព គោតក្រែងនូវគ្នានឹងគ្នា[២២]។

## ដល់ពេលធ្វើសង្គាយនាទៀតឬនៅ

ពីអតីតកាល គ្រាន់តែមានរឿងបន្តិចដូចជាសុភទ្ទភិក្ខុបួសឯចាស់ ពោលពាក្យចម្រូងចម្រាស់ក្នុងពុទ្ធសាសនាថា ព្រះពុទ្ធបរិនិព្វានទៅ ពួកយើងស្រួលហើយ ចង់ធ្វើអីក៏បានដែរ អស់មាននរណាមកស្តីបន្ទោសអីទៀតហើយ។ រឿងប៉ុណ្ណឹង គេចាប់ធ្វើសង្គាយនា លើកទី ១ ភ្លាម។ ក្រោយមក ពួកវជ្ជីបុត្តភិក្ខុលើកឡើងនូវវត្ថុ ១០ ប្រការថា ភិក្ខុអាចសន្សំអំបិលទុកក្នុងខ្លាក់ស្នែង ហើយយកមកឆាន់ជាមួយអាហារក៏បាន- -ថ្ងៃជ្រេទៅត្រឹមតែ ២ ធ្នាប់ ភិក្ខុអាចឆាន់ចង្ហាន់បាន។ តែប៉ុណ្ណឹងគេនាំគ្នាធ្វើសង្គាយនាលើកទី ២ ។

[២២] *សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត ៤៥/២៣៧។*

ចុះសម័យបច្ចុប្បន្ន ភិក្ខុសង្ឃគ្មានប្រព្រឹត្តខុសចាកធម៌វិន័យទេឬអ្វី? បើតាមខ្ញុំដឹងឮមានកំហុសច្រើនណាស់ កំហុសយ៉ាងធ្ងន់ៗក៏មានដែរ។ សុភទ្ទភិក្ខុ គ្រាន់តែថា ព្រះពុទ្ធបរិនិព្វានទៅពួកយើងស្រួលហើយ ឯភិក្ខុសម័យបច្ចុប្បន្នហ៊ានដល់ប្រមាថមើលងាយព្រះពុទ្ធទៀតផង។ ពួកវជ្ជីបុត្តភិក្ខុ គ្រាន់តែថា ថ្ងៃជ្រេត្រឹម ២ ធ្នាប់ ភិក្ខុអាចឆាន់ចង្ហាន់បាន ឯភិក្ខុសម័យបច្ចុប្បន្នហ៊ានដល់ទៅឆាន់ចង្ហាន់ពេលយប់ទៀតក៏មានដែរ។ កំហុសពីដើម ច្រើនតែអ្នកតូចនាំធ្វើ កំហុសសម័យឥឡូវ ច្រើនតែអ្នកធំៗ នាំធ្វើ។ បើគោមេហ្វូងនាំដើរយ៉ាងនេះ តើគោកូនហ្វូងនឹងដើរដូចម្ដេចទៅវិញ វាទៅទាំងប៉ឹ ទាំងស្គរអស់ទៅហើយ។

ពីសម័យមុនៗ គេធ្វើសង្គាយនា ដើម្បីរម្ងាប់អធិករណ៍ផង ដើម្បីពិនិត្យផ្ទៀងផ្ទាត់ធម៌វិន័យផង ឯសម័យក្រោយៗ គេធ្វើសង្គាយនាដើម្បីត្រឹមតែពិនិត្យគម្ពីរតែប៉ុណ្ណោះ ពិនិត្យគម្ពីរ ពិនិត្យច្បាប់ តែមិនរវល់នឹងអ្នកខុសច្បាប់សោះទេ បើដូចនេះ តើវាយ៉ាងម៉េចទៅដែរ។ នរណាគិត នរណាដោះស្រាយរឿងនេះ។

ពេលវេលាធ្វើសង្គាយនាមកដល់យូរណាស់ហើយ ប៉ុន្តែគ្មាននរណាគិត លោកគ្រូតូចៗ ជួយពិនិត្យ ជួយគិតជួយប្រាប់លោកគ្រូធំដែរ តែលោកគ្រូធំ ក៏នៅតែមិនគិត គិតតែពីខំអួត... កុំថាឡើយរឿងសង្គាយនា សូម្បីតែរឿងអធិករណ៍ពុករលួយក្នុងវត្តក៏លោកមិនសូវគិតដែរ ម៉េចលោកនឹងគិត បើគិតទៅនាំប៉ះពារ នាំពិបាក នាំខាត ម្ល៉ោះហើយ លោកត្រូវតែខំសម្ងំយក... សិនទៅស្រួលជាង។

ឥឡូវពឹងឧបាសក ឧបាសិកា ឲ្យជួយគិត ឧបាសក ឧបាសិកា ខ្លះគេថា កុំទៅលែងជាមួយនឹងភ្លើង រឿងរបស់លោកសង្ឃ ស្រេចលើលោកសង្ឃចុះ យើងគិតតែពីធ្វើបុណ្យទៅ...។ ធ្វើបុណ្យផ្ទុកក្នុងសំពៅធ្លុះនោះឬ? សាសនាស្ថិតនៅបានយូរដោយសារពុទ្ធបរិស័ទ គឺ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ចុះបើនាំគ្នាមិនគិតមិនដោះស្រាយ មិនបដិបត្តិ តើវាយ៉ាងម៉េចទៅ សូមនាំគ្នាខំប្រឹងប្រែងឡើង ប្រយ័ត្ន សាសនាដទៃ គេយកអស់៕

# ខន្តីធម៌

ទោសៈនេះខ្លាំង		កម្លាំងក្រៃលែង
តែឲ្យដុះវែង		គ្មានអ្វីខ្លាំងដូច។
ត្រូវកាត់ពីតិច		ត្រូវក្តិចពីតូច
ត្រូវគេចឲ្យរួច		ពីទោសដែលខឹង។
អ្នកប្រាជ្ញបុរាណ		បានឲ្យដំណឹង
ជាអ្នកមិនខឹង		ទើបហៅខន្តី។
ឲ្យគេឈ្នះចុះ		យើងកុំខ្មាសអី
មិនខឹងមិនស្តី		ខន្តីបានយើង។
ខន្តីជាឫស		ដុះជាបណ្តូល
ខន្តីជាមូល		មេធម៌ទាំងអស់។
ខន្តីជាស្ពាន		ជាយានសប្បុរស
អ្នកប្រាជ្ញទាំងអស់		អាស្រ័យខន្តី។
ទៅសួគ៌និព្វាន		គ្មានទៅដោយអ្វី
ទៅដោយខន្តី		ជាស្ពានដំណើរ។
ខន្តីនេះសុខ		ផុតទុក្ខប្រសើរ
មិនចាំបាច់ធ្វើ		ទ្រព្យហូរចូលឯង។
ខន្តីជាទ្រព្យ		គួរគាប់ជាក់ស្តែង
អ្នកផងស្ញប់ស្ញែង		កោតក្រែងគ្រប់គ្នា។
ទាំងមនុស្សទេវតា		ឈមនៅទីណា
បានសុខគ្រប់យ៉ាង		សូមតឿនលោកអ្នក។
គ្រប់ជាន់គ្រប់ថ្នាក់		ដែលមានសំណាង
ធ្វើបុណ្យកសាង		កុំចោលខន្តី។
ទានសីលភាវនា		សមាធិក្តី
តែខ្វះខន្តី		គ្មានអ្វីទល់ទប់។
ខន្តី សច្ចៈ		ទុកជាទំនប់
ចន្ទល់ពិភព		ជាម្លប់សាសនា។

ជាទីជ្រកកោន នៃមនុស្សទេវតា
ដែលបានសុខា ដោយសារខន្តី ។
រឿងនេះសង្ខេប ជាបែបខ្លីៗ
ឯរំ សេចក្តី ថាចប់ហើយហោង[២៣] ៕

## ឧទ្ទិសកថា

សូមឧទ្ទិសចំណែកបុណ្យកុសលនេះ ជូនចំពោះវិញ្ញាណក្ខន្ធ នៃលោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ចំពោះញាតិមិត្រទាំងឡាយផង ។

សូមលោកអ្នកដ៏មានគុណជាដើមនោះ អនុមោទនាទទួលយកនូវឥដ្ឋមនុញ្ញផលជាទីគាប់ចិត្តនេះ តាមសេចក្តីជ្រះថ្លារៀងៗ ខ្លួនកុំបីអាក់ខានឡើយ ។ ៚

[២៣] *កំណាព្យនេះ បានមកពីឧបាសិកា ស៊ីវ ចាប់ អាយុ ៩២ ឆ្នាំហើយ នៅចេះចាំធម៌ច្រើន និងអាចអញ្ជើញទៅធ្វើទាន សីល ភាវនាបាននៅឡើយ ។*